ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ.....៧៤៤៨៧.....អពដ

GENERAL DEPARTMENT OF TAXATION

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ កញ្ញា ឆ្នាំ២០១៥

# សេចក្តីជូនដំណឹង

## ស្តីពីការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស សម្រាប់សហគ្រាស ឬក្រុមហ៊ុន ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ

អនុលោមតាមច្បាប់ស្តីពីសារពើពន្ធ និងប្រកាសលេខ ១១៣៩ សហវ.ប្រក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការចុះបញ្ជីពន្ធដារ អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយសសូមជម្រាបជូនដំណឹងដល់ លោក-លោកស្រី ជាប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាល ឬម្ចាស់សហគ្រាស ដែលមានក្រុមហ៊ុនកំពុងស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំទាំងអស់ជ្រាបថា កន្លងមកមានសហគ្រាស ឬក្រុមហ៊ុនដែលបានចុះបញ្ជីពន្ធដារមុនថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៤ ជាច្រើនបានចូលរួមសហការជាមួយអគ្គនាយកដ្ឋានពន្ធដារ មកធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសតាមការជូនដំណឹង។ ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋានពន្ធដារសង្កេតឃើញថា នៅមានសហគ្រាស ឬក្រុមហ៊ុន មួយចំនួននៅតែមិនទាន់មកធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសនៅឡើយ។

ដើម្បីឱ្យការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសប្រព្រឹត្តទៅបានទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ អគ្គនាយកដ្ឋានពន្ធដារ សូមជម្រាបជូនលោក លោកស្រី ជាម្ចាស់សហគ្រាស ឬក្រុមហ៊ុន ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំទាំងអស់ដែលមិនទាន់បានមកធ្វើបច្ចុប្បន្នភាពព័ត៌មានជ្រាបថា ការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស នឹងត្រូវបញ្ចប់ជាស្ថាពរត្រឹមថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៥ នេះ។

ក្នុងករណីសហគ្រាស ឬក្រុមហ៊ុន មិនបានមកធ្វើបច្ចុប្បន្នភាពព័ត៌មានតាមកាលបរិច្ឆេទកំណត់ខាងលើនេះ ចាប់ពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥ តទៅ អគ្គនាយកដ្ឋានពន្ធដារនឹងចាត់វិធានការមួយចំនួន ដូចខាងក្រោម ÷

១. ទុកជាមោឃៈនូវវិញ្ញាបនបត្រអាករលើតម្លៃបន្ថែមដែលបានចុះបញ្ជីពន្ធដារមុនថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៤ (វិញ្ញាបនបត្រអាករលើតម្លៃបន្ថែមតាមប្រព័ន្ធចាស់)
២. មិនអនុញ្ញាតឱ្យស្នើសុំជាឥណទានយោងអាករលើធាតុចូល ឬស្នើសុំបង្វិលសងប្រាក់អាករលើតម្លៃបន្ថែមឡើយ
៣. ស្នើសុំសហការពីអគ្គនាយដ្ឋានគយ និងរដ្ឋាករកម្ពុជាបញ្ឈប់ប្រតិបត្តិការនាំចេញ នាំចូល
៤. ស្នើសុំសហការពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាផ្អាកការពិនិត្យសំណើសុំនាំចូលវត្ថុធាតុដើម គ្រឿងម៉ាស៊ីន និងសម្ភារបរិក្ខារ និង
៥. វិធានការផ្សេងៗទៀតតាមច្បាប់ជាធរមាន

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមនិងជឿជាក់ថា លោក-លោកស្រី ប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាល ឬម្ចាស់សហគ្រាសទាំងអស់ ពិតជាយកចិត្តទុកដាក់រួសរាន់អញ្ជើញមកធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស តាមការជូនដំណឹងនេះ។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល

Collection by VCAT Professional Consultant